# ការស្ទង់មតិអំពីសមធម៌ផ្នែកសុខភាពសហគមន៍ឆ្នាំ ២០២៣

# សំណួរ ដែលគេ ច្រើន សួរ

## អ្នកបំពេញការស្ទង់មតិ

- **តើការស្ទង់មតិនេះ មានលក្ខណៈបែបណា?**
  - ការស្ទង់មតិអំពីសមធម៌សុខភាពសហគមន៍ គឺជាការស្ទង់មតិលក្ខណៈអាណាមិកតាមអនឡាញ។ លទ្ធផលនឹងជួយដល់ក្រសួងសុខភាពសាធារណៈនៃរដ្ឋម៉ាសាឈូសិត និងសហគមន៍នានានៅទូទាំងរដ្ឋ ធ្វើការផ្លាស់ប្តូរស្ថានភាពដែលរារាំងដល់សុខភាព។
  - ការស្ទង់មតិនេះ ត្រូវបានបង្កើតឡើងដោយមានកិច្ចសហប្រតិបត្តិការជាមួយសមាជិក និងដៃគូសហគមន៍នៅទូទាំងរដ្ឋ។ សំណួរស្ទង់មតិត្រូវផ្អែកលើបទពិសោធនិងតម្រូវការរបស់ពលរដ្ឋរស់នៅក្នុងរដ្ឋម៉ាសាឈូសិត។
  - ការស្ទង់មតិនេះសាកសួរអំពីចំណុចដែលប៉ះពាល់ដល់សុខភាពរបស់លោកអ្នក។ ប្រធានបទនៃការស្ទង់មតិនេះ រួមមាន ការទទួលបានការថែទាំសុខភាព និងការដឹកជញ្ជូន សុខភាពផ្លូវកាយនិងផ្លូវចិត្ត និងសុខុមាលភាព បទពិសោធពាក់ព័ន្ធនឹងជំងឺកូវីដ-19 បញ្ហាលំនៅដ្ឋាន ការអប់រំ និងការងារ។ ការស្ទង់មតិនេះ ក៏សាកសួរព័ត៌មានអំពីអាយុ ភេទ និងជាតិសាសន៍ផងដែរ។

- **តើការស្ទង់មតិនេះ នឹងជួយជាប្រយោជន៍ដល់សហគមន៍របស់ខ្ញុំយ៉ាងដូចម្តេចខ្លះ?**
  - **ការស្ទង់មតិនេះនឹងជួយធ្វើឱ្យប្រាកដថា តម្រូវការនិងចំណុចអាទិភាពរបស់សហគមន៍លោកអ្នក នឹងបង្ហាញនៅក្នុងទិន្នន័យនេះ។** ចម្លើយរបស់លោកអ្នកចំពោះការស្ទង់មតិនេះ នឹងបង្ហាញអំពីចំណុចដែលជួយដល់សហគមន៍ឱ្យមានសុខភាពល្អ និងចំណុចដែលធ្វើឱ្យសហគមន៍កាន់តែពិបាកនឹងមានសុខភាពល្អបាន។
  - ក្រសួងសុខភាពសាធារណៈនៃរដ្ឋម៉ាសាឈូសិត នឹងប្រើប្រាស់ទិន្នន័យពីការស្ទង់មតិនេះ ដើម្បីដឹកនាំការងាររបស់យើង។ ចំណុចនេះរួមបញ្ចូលទាំងការកែលម្អកម្មវិធីរបស់យើងខ្ញុំ ការធ្វើសេចក្តីសម្រេចចិត្តអំពីមូលនិធិ និងធនធាន និងការគាំទ្រដល់គោលនយោបាយនានា ដើម្បីកែលម្អបញ្ហាវិសមភាពសុខភាពផងដែរ។ យើងក៏នឹងចែករំលែកលទ្ធផលនៃការស្ទង់មតិនេះជាមួយដៃគូផ្សេងៗនៅទូទាំងរដ្ឋម៉ាសាឈូសិតផងដែរ ដើម្បីគាំទ្រដល់កិច្ចការសំខាន់ៗដែលពួកគេកំពុងធ្វើ ដើម្បីលើកកម្ពស់សុខភាពសហគមន៍របស់ពួកគេ។

- **តើនរណាដែលអាចបំពេញការស្ទង់មតិនេះបាន?**
  - មនុស្សគ្រប់គ្នាដែលមានអាយុចាប់ពី 14 ឆ្នាំឡើងទៅ ដែលរស់នៅក្នុងរដ្ឋម៉ាសាឈូសិតពេញមួយឆ្នាំ ឬក្នុងពេលខ្លះ អាចបំពេញការស្ទង់មតិនេះបាន។

- **តើខ្ញុំអាចបំពេញការស្ទង់មតិនេះជាភាសាអ្វីបានខ្លះ?**
  - លោកអ្នកអាចបំពេញការស្ទង់មតិនេះ ជាភាសាដូចខាងក្រោម៖ ភាសាអារ៉ាប់ ភាសាកាបវែក្រេអូល ភាសាចិន (ធម្មតា និងបូរាណ) ភាសាអង់គ្លេស ភាសាហៃទីក្រេអូល

ភាសាខ្មែរ ភាសាព័រទុយហ្គាល់ ភាសារុស្ស៊ី ភាសាអេស្ប៉ាញ ភាសាវៀតណាម។ ការស្ទង់មតិនេះក៏នឹងមានផ្តល់ជូនជាភាសាសញ្ញាអាមេរិក នៅពេលក្រោយទៀតក្នុងរដូវក្តៅនេះផងដែរ។
  - ប្រសិនបើលោកអ្នកចង់បាន អ្នកផ្សេងអាចបកប្រែសំណួរទៅជាភាសាដែលលោកអ្នកចង់បាន និងបំពេញការស្ទង់មតិនេះជំនួសលោកអ្នកបាន។

- **តើខ្ញុំអាចបំពេញការស្ទង់មតិនេះបានដោយរបៀបណា?**
  - ការស្ទង់មតិនេះ នឹងមានផ្តល់ជូនតាមអនឡាញ នៅទីនេះ នៅថ្ងៃទី31 ខែកក្កដា ឆ្នាំ2023 ហើយនឹងត្រូវបិទបញ្ចប់នៅខែតុលា។

- **នៅពេលខ្ញុំបំពេញការស្ទង់មតិនេះ តើខ្ញុំគួររំពឹងអ្វីខ្លះ?**
  - បន្ទាប់ពីចុចនៅលើតំណភ្ជាប់នេះ លោកអ្នកនឹងអាចជ្រើសរើសភាសាដែលលោកអ្នកចង់បាន ដើម្បីបំពេញការស្ទង់មតិនេះ។ ការស្ទង់មតិនេះ អាចចំណាយពេលចន្លោះពី 15-30 នាទី។
  - លោកអ្នកនឹងឃើញសំណួរពាក់ព័ន្ធនឹងប្រធានបទដូចជា ការទទួលបានការថែទាំសុខភាព និងការដឹកជញ្ជូន សុខភាពផ្លូវកាយនិងផ្លូវចិត្ត និងសុខុមាលភាព បទពិសោធពាក់ព័ន្ធនឹងជំងឺកូវីដ-19 បញ្ហាលំនៅដ្ឋាន ការអប់រំ និងការងារជាដើម។
  - ការស្ទង់មតិនេះ ស្នើសុំព័ត៌មានអំពីលោកអ្នក ដូចជា អាយុ ជនជាតិ និងភេទ។ នេះនឹងជួយដល់យើងខ្ញុំក្នុងការយល់ដឹងថាតើមានតម្រូវការនិងបទពិសោធខុសៗគ្នាដូចម្តេចខ្លះនៅតាមក្រុមនីមួយៗ។
  - លោកអ្នកអាចចាកចេញពីការស្ទង់មតិនេះបានគ្រប់ពេល និងអាចរំលងសំណួរណាមួយក៏បាន ប្រសិនបើលោកអ្នកចង់។

- **តើការស្ទង់មតិនេះ មានលក្ខណៈអាណាមិកដែរឬទេ?**
  - ការស្ទង់មតិធ្វើឡើងដោយការស្ម័គ្រចិត្ត និងមានលក្ខណៈអាណាមិកទាំងស្រុង។ ការស្ទង់មតិនេះ ពុំសួរពីព័ត៌មានណាមួយដែលអាចត្រូវបានគេប្រើដើម្បីកំណត់អត្តសញ្ញាណរបស់លោកអ្នកឡើយ ហើយចម្លើយរបស់លោកអ្នក មិនអាចតាមដានត្រឡប់ទៅរកលោកអ្នកវិញតាមវិធីណាមួយបានឡើយ។

- **តើនរណាបានចូលទៅមើលចម្លើយរបស់ខ្ញុំខ្លះ?**
  - មនុស្សមួយចំនួនដែលធ្វើការក្រសួងសុខភាពសាធារណៈ នឹងអាចចូលទៅមើលចម្លើយនៃស្ទង់មតិលក្ខណៈអាណាមិកនេះបាន។ បន្ទាប់ពីបិទការស្ទង់មតិ លទ្ធផលនេះត្រូវចែករំលែកជាមួយដៃគូសហគមន៍ ដើម្បីឱ្យពួកគេអាចប្រើប្រាស់ព័ត៌មាន ដើម្បីស្វែងយល់ពីទីកន្លែង និងរបៀបដែលល្អបំផុតក្នុងការផ្តល់ជូនធនធានដើម្បីលើកកម្ពស់សុខភាព។
  - ទិន្នន័យសង្ខេបក៏នឹងមានផ្តល់ជូនដល់មនុស្សគ្រប់គ្នានៅលើគេហទំព័ររបស់យើងខ្ញុំតាមរយៈតារាងទិន្នន័យ ការធ្វើបទបង្ហាញដែលបានថតទុក និងផ្ទាំងទិន្នន័យ។ ឯកជនភាពរបស់ពលរដ្ឋដែលបំពេញការស្ទង់មតិ សំខាន់ចំពោះយើងខ្ញុំខ្លាំងណាស់ ហើយចម្លើយរបស់លោកអ្នក មិនអាចកំណត់អត្តសញ្ញាណរបស់លោកអ្នកដោយប្រការណាមួយបានឡើយ។

- **ខ្ញុំមានសំណួរជាច្រើនទៀត។ តើខ្ញុំអាចទាក់ទងទៅនរណាបានខ្លះ?**

- ប្រសិនបើលោកអ្នកមានសំណួរបន្ថែមអំពីការស្ទង់មតិនេះ ឬអាចត្រូវការឱ្យគេជួយក្នុងការបំពេញការស្ទង់មតិនេះ សូមផ្ញើអ៊ីម៉ែលទៅកាន់ chei@mass.gov។

## ដៃគូសហគមន៍

- **តើអ្វីទៅជាសហគមន៍គោលដៅ?**
  - និយាយឱ្យងាយយល់ទៅ សហគមន៍គោលដៅ គឺជាក្រុមដែលមានប្រវត្តិធ្លាប់ត្រូវបានគេបដិសេធពីមុនមក ហើយបច្ចុប្បន្នកំពុងត្រូវបានគេបដិសេធមិនឱ្យមានឱកាសទទួលសុខភាពស្មើភាពគ្នា។ សម្រាប់ការស្ទង់មតិឆ្នាំ2023 នេះ សហគមន៍គោលដៅ គឺជាប្រជាជនដែលមានលក្ខណៈសម្គាល់ដូចខាងក្រោម៖
    - មនុស្សចាស់ (អាយុ 60+)
    - ឪពុកម្តាយ និងអ្នកមើលថែទាំកុមារ និងយុវជនដែលមានតម្រូវការថែទាំសុខភាពពិសេស
    - ឪពុកម្តាយដែលមានអាយុក្រោម 25 ឆ្នាំ
    - មនុស្សដែលកំណត់អត្តសញ្ញាណជា LGBTQ+
    - ជនជាតិមិនមែនស្បែកស (រួមមាន ពលរដ្ឋជាជនជាតិអាមេរិកាំងស្បែកក្រហម/ជនជាតិដើមអាឡាស្កា ជនជាតិអាមេរិកាំងដើមកំណើតអាស៊ី/អ្នកកោះបាស៊ីហ្វិក ជនជាតិស្បែកខ្មៅ និងជនជាតិអេស្ប៉ាញ/ឡាទីន)
    - ពលរដ្ឋដែលមានភាសាកំណើតមិនមែនជាភាសាអង់គ្លេស
    - ពលរដ្ឋដែលមានពិការភាព
    - ពលរដ្ឋដែលមានបទពិសោធធ្វើអន្តោប្រវេសន៍
    - ស្ត្រីមានផ្ទៃពោះ និងឪពុកម្តាយដែលមានកូនតូច
    - ពលរដ្ឋរស់នៅតាមទីជនបទ
    - អតីតយុទ្ធជន
    - យុវជន និងមនុស្សក្នុងបឋមវ័យ (អាយុពី 14-24 ឆ្នាំ)

- **តើខ្ញុំអាចជួយមនុស្សនៅក្នុងសហគមន៍របស់ខ្ញុំក្នុងការបំពេញការស្ទង់មតិនេះបានតាមរបៀបណា?**
  - លោកអ្នកស្គាល់សហគមន៍លោកអ្នកច្បាស់ជាងគេបំផុត! យើងខ្ញុំនៅទីនេះ ហើយពេញចិត្តនឹងជួយគាំទ្រលោកអ្នក។ ខាងក្រោមនេះ គឺជាវិធីមួយចំនួនដែលយើងខ្ញុំសូមណែនាំឱ្យជួយកៀរគរសមាជិកសហគមន៍បំពេញការស្ទង់មតិនេះ៖
    - ចែករំលែកព័ត៌មានអំពីការស្ទង់មតិនេះ! យើងមានធនធាននានាដូចជា គំរូអ៊ីម៉ែល ភាសាបណ្តាញសង្គម និងផូស្ទ័រ ដែលលោកអ្នកអាចប្រើដើម្បីជួយផ្សព្វផ្សាយដំណឹងនេះទៅកាន់លោកអ្នកដែលទំនងជាចូលរួមក្នុងការស្ទង់មតិនេះ ទៅកាន់មិត្តភ័ក្តិ គ្រួសារ និងមិត្តរួមការងារ។
    - ធ្វើការសន្ទនាគ្នាជាមួយយើងខ្ញុំ! យើងខ្ញុំរីករាយនឹងពិភាក្សាអំពីគំនិតផ្សេងៗជាមួយលោកអ្នក។
    - ជួយយើងក្នុងការបង្កើតបណ្តាញដៃគូ! ប្រសិនបើលោកអ្នកស្គាល់ដៃគូសហគមន៍ដែលអាចចាប់អារម្មណ៍ក្នុងការធ្វើការងារជាមួយយើងខ្ញុំ សូមចែករំលែកគេហទំព័រ និងព័ត៌មានទំនាក់ទំនងរបស់យើងខ្ញុំជាមួយពួកគេ។

ធនធាននានាដែលអាចប្រើប្រាស់ដើម្បីជួយចែករំលែក និងផ្សព្វផ្សាយពីការស្ទង់មតិនេះនៅក្នុងសហគមន៍របស់លោកអ្នក មាននៅលើគេហទំព័ររបស់យើងខ្ញុំ៖ www.mass.gov/chei។
លោកអ្នកអាចទាក់ទងមកកាន់យើងខ្ញុំបាន តាមរយៈ chei@mass.gov។

- **តើខ្ញុំអាចចូលទៅប្រើទិន្នន័យទាំងនេះបានដោយរបៀបណានិងនៅពេលណា?**
  - យើងខិតខំប្រឹងប្រែងដើម្បីធ្វើឱ្យដំណើរការនេះមានលក្ខណៈសាមញ្ញ និងមានតម្លាភាពតាមដែលអាចធ្វើទៅបាន។ លទ្ធផលនឹងអាចស្វែងរកបានជាសាធារណៈនៅលើគេហទំព័ររបស់យើងឆាប់ៗបន្ទាប់ពីការស្ទង់មតិនេះត្រូវបានបិទនៅរដូវស្លឹកឈើជ្រុះឆ្នាំ2023 ហើយ DPH នឹងផ្តល់ជូនដល់ដៃគូដូចជាលោកអ្នក នូវធនធាននានាដើម្បីប្រើប្រាស់ទិន្នន័យនេះ ដើម្បីដោះស្រាយឧបសគ្គបញ្ហាសុខភាពនៅក្នុងសហគមន៍របស់លោកអ្នក។

- **តើខ្ញុំអាចទទួលបានជំនួយក្នុងការវិភាគទិន្នន័យនេះដែរឬទេ?**
  - អាចទទួលបាន! យើងខ្ញុំនឹងមានជំនួយគាំទ្រមួយចំនួនផ្តល់ជូននៅក្នុងរដូវស្លឹកឈើជ្រុះឆ្នាំ2023 នៅពេលដែលលទ្ធផលនៃការស្ទង់មតិនេះត្រូវបានចុះផ្សាយជាសាធារណៈ។ ពេលនោះ សូមចូលទៅមើលគេហទំព័ររបស់យើងសាជាថ្មី (www.mass.gov/chei) ឬទាក់ទងមកកាន់យើងខ្ញុំដើម្បីបានបញ្ជីទិន្នន័យជំនួយគាំទ្រដល់មានផ្តល់ជូនដែលបានធ្វើបច្ចុប្បន្នភាពថ្មីៗបំផុត។

- **តើខ្ញុំអាចប្រើប្រាស់លទ្ធផលរកឃើញទាំងនេះដើម្បីផ្តល់ប្រយោជន៍ដល់សហគមន៍ខ្ញុំតាមរបៀបណា?**
  - នៅពេលដែលលោកអ្នកវិភាគទិន្នន័យសម្រាប់សហគមន៍របស់លោកអ្នក លោកអ្នកអាចរំលេចពីតម្រូវការដែលបំពេញមិនទាន់បាន ដែលនឹងផ្តល់ប្រយោជន៍ដល់វិធានការសុខភាពសាធារណៈ។ ខាងក្រោមនេះ គឺជាឧទាហរណ៍ខ្លះអំពីការរំលេចឱ្យឃើញពីបញ្ហានេះតាមរយៈការស្ទង់មតិផលប៉ះពាល់សហគមន៍ដោយសារជំងឺកូវីដ-19 ឆ្នាំ2020៖
    - <u>សហគមន៍ LGBTQ+</u>៖ ទិន្នន័យការស្ទង់មតិផលប៉ះពាល់សហគមន៍ដោយសារជំងឺកូវីដ-19 ត្រូវបានប្រើប្រាស់ដោយគណៈកម្មការយុវជន LGBTQ រដ្ឋម៉ាសាឈូសិត ដើម្បីធ្វើការតស៊ូមតិដើម្បីគោលនយោបាយដែលផ្តោតសំខាន់លើតម្រូវការរបស់សហគមន៍។ ទិន្នន័យនេះក៏ត្រូវបានប្រើប្រាស់ដើម្បីតស៊ូមតិដើម្បីដាក់បញ្ចូលពលរដ្ឋ LGBTQ+ ជាពលរដ្ឋអាទិភាពសម្រាប់គំនិតផ្តួចផ្តើមសមធម៌វ៉ាក់សាំង ដែលផ្តល់ធនធាននិងមូលនិធិសហគមន៍បន្ថែម។
    - <u>សហគមន៍ជនជាតិភាគតិច</u>៖ ទិន្នន័យការស្ទង់មតិផលប៉ះពាល់សហគមន៍ដោយសារជំងឺកូវីដ-19 ត្រូវបានប្រើប្រាស់ដើម្បីអនុវត្តប្រកបដោយជោគជ័យនូវមូលនិធិច្រើនជាង 1$ លានដុល្លារ ផ្តល់ជូនទៅកុលសម្ព័ន្ធ និងជនជាតិភាគតិចដែលបម្រើការនៅស្ថាប័នផ្សេងៗ។
    - <u>សហគមន៍ជនបទ</u>៖ ទិន្នន័យការស្ទង់មតិផលប៉ះពាល់សហគមន៍ដោយសារជំងឺកូវីដ-19 ត្រូវបានប្រើប្រាស់ដើម្បីជួយគាំទ្រដល់កម្មវិធីផ្សព្វផ្សាយអំពីការចាក់វ៉ាក់សាំង និងកម្មវិធីមូលនិធិដើម្បីជួយគាំទ្រដល់ស្ថាប័នតាមទីជនបទ ក្នុងការដោះស្រាយឧបសគ្គសុខភាពនៅក្នុងសហគមន៍របស់ពួកគេ។

- ឪពុកម្តាយវ័យក្មេង៖ ទិន្នន័យការស្ទង់មតិផលប៉ះពាល់សហគមន៍ដោយសារជំងឺកូវីដ-19 បង្ហាញពីការមិនបានបំពេញតាមតម្រូវការយ៉ាងច្រើនក្នុងចំណោមឪពុកម្តាយវ័យក្មេង។ ក្រោយពេលបញ្ចេញទិន្នន័យ សេវាកម្មដែលផ្តល់ជូនញឹកញាប់បំផុតដោយគំនិតផ្តួចផ្តើមយុវវ័យមានផ្ទៃពោះ និងចិញ្ចឹមបីបាច់កូនក្នុងរដ្ឋម៉ាសាឈូសិត មានដូចជា ប្រាក់ឈ្នួលផ្ទះ លំនៅដ្ឋាន និងជំនួយសេវាទឹកភ្លើង។
- យុវជន៖ បន្ទាប់ពីទិន្នន័យការស្ទង់មតិផលប៉ះពាល់សហគមន៍ដោយសារជំងឺកូវីដ-19 ត្រូវបានបញ្ចេញ សុខភាពផ្លូវចិត្តរបស់យុវជនត្រូវបានចាត់ទុកជាចំណុចអាទិភាពនៅក្នុងក្រសួងសុខភាពសាធារណៈ (DPH)។ ទិន្នន័យត្រូវបានប្រើប្រាស់សម្រាប់ការធ្វើលទ្ធកម្មនៃសេវាកម្មថ្មីៗពីសំណាក់កម្មវិធីសេវាបង្ការអំពើហិង្សាលើកុមារនិងយុវជន។
- អ្នកទទួលបានសេវាពី WIC៖ ទិន្នន័យការស្ទង់មតិផលប៉ះពាល់សហគមន៍ដោយសារជំងឺកូវីដ-19 ត្រូវបានប្រើប្រាស់ដោយកម្មវិធី WIC ដើម្បីផ្តោតលើសារៈសំខាន់និងតម្រូវការសម្រាប់លទ្ធភាពទទួលបានសេវាភាសានៅក្នុងការផ្សព្វផសាយរបស់ WIC ដើម្បីធានាថា ក្រុមគ្រួសារដែលនិយាយភាសាផ្សេងក្រៅពីភាសាអង់គ្លេស អាចទទួលបានសេវាកម្មរបស់ WIC។
- កុមារដែលមានតម្រូវការការថែទាំសុខភាពពិសេស៖ ការស្ទង់មតិផលប៉ះពាល់សហគមន៍ដោយសារជំងឺកូវីដ-19 ទិន្នន័យការស្ទង់មតិផលប៉ះពាល់សហគមន៍ដោយសារជំងឺកូវីដ-19 បានបង្ហាញពីចំណុចអាទិភាពជាក់លាក់ (សុខភាពផ្លូវចិត្ត សន្តិសុខស្បៀង និងការផ្លាស់ប្តូរការថែទាំសុខភាពដែលកើតមាននៅអាយុ 18 ឆ្នាំ)។ ចំណុចអាទិភាពទាំងនេះ ត្រូវបានប្រើប្រាស់នៅក្នុងមុខងារផ្តល់មូលនិធិជាច្រើន ដើម្បីលើកកម្ពស់សេវាកម្មសម្រាប់កុមារដែលមានតម្រូវការការថែទាំសុខភាពពិសេស។
- កុមារ៖ ទិន្នន័យការស្ទង់មតិផលប៉ះពាល់សហគមន៍ដោយសារជំងឺកូវីដ-19 ត្រូវបានចែករំលែកជាមួយសម្ព័ន្ធបណ្ឌិតសភាគ្រូពេទ្យកុមារអាមេរិកនៃរដ្ឋម៉ាសាឈូសិត។ លទ្ធផលរកឃើញទាំងអស់នេះ ផ្តល់ជាភស្តុតាងដល់ពួកគេក្នុងការផ្តល់អាទិភាពបន្ថែមទៅលើសុខភាពផ្លូវចិត្ត ការផ្លាស់ប្តូរការថែទាំសុខភាព និងកត្តាកំណត់ផ្នែកសង្គមទៅលើបញ្ហាសុខភាពនៅក្នុងការងាររបស់ពួកគេ។
- អ្នកទទួលបានសេវា Medicaid៖ ទិន្នន័យការស្ទង់មតិផលប៉ះពាល់សហគមន៍ដោយសារជំងឺកូវីដ-19 ត្រូវបានចែករំលែកជាមួយ MassHealth ដើម្បីផ្តល់ដំណឹងដល់ការដាក់ពាក្យស្នើសុំបដិសេធការទទួលខុសត្រូវ 1115 ដែលពង្រីកបន្ថែមការរ៉ាប់រងរបស់ Medicaid និងការទទួលបានការថែទាំ។
- ពលរដ្ឋដែលមានពិការភាព៖ ក្រសួងសុខភាពសាធារណៈ (DPH) ផ្តោតអាទិភាពលើការលើកកម្ពស់ការទទួលបានវ៉ាក់សាំងទៅកាន់ពលរដ្ឋដែលមានពិការភាព។ នៅក្នុងមជ្ឈដ្ឋានពិការភាព ពលរដ្ឋដែលទំនងជានឹងមិនត្រូវទទួលបានការចាក់វ៉ាក់សាំង ត្រូវបានគេចាក់វ៉ាក់សាំងជូន មួយផ្នែកធំ ក៏ដោយសារបានទិន្នន័យការស្ទង់មតិផលប៉ះពាល់សហគមន៍ដោយសារជំងឺកូវីដ-19 នេះដែរ។

- **ខ្ញុំមានសំណួរជាច្រើនទៀត។ តើខ្ញុំអាចទាក់ទងទៅនរណាបានខ្លះ?**
  - ប្រសិនបើលោកអ្នកមានសំណួរផ្សេងៗអំពីការស្ទង់មតិនេះ ឬអាចត្រូវការឱ្យគេជួយក្នុងការចូលទៅមើល ឬវិភាគទិន្នន័យនេះ សូមផ្ញើអ៊ីម៉ែលទៅកាន់ chei@mass.gov។